## ពុទ្ធិកសមាគមខ្មែរ វត្តមុនីសុតារាម រដ្ឋមិនីសូតា

THE MINNESOTA CAMBODIAN BUDDHIST SOCIETY; INC.
A NON-PROFIT RELIGIOUS INCORPORATION
2925 220th Street East, Hampton, MN 55031 Tel: (651) 463-3101 Fax: (651) 460-4464
http://www.wattmunisota.org


# បុណ្យពុទ្ធាភិសេក បុណ្យបញ្ចុះសីមា សម្ពោធឆ្លងព្រះវិហារថ្មី

◉ ◉ ◉ ◉ ◉ ◉ ◉ ◉ ◉

ខ្ញុំព្រះករុណាអាត្មាភាព ព្រះចៅអធិការវត្ត ព្រះសង្ឃ ព្រមទាំងក្រុមអភិបាល នៃពុទ្ធិកសមាគមខ្មែរ និង ពុទ្ធបរិស័ទ វត្តមុនីសុតារាម រដ្ឋមិនីសូតា សូមប្រគេនដំណឹងដល់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ សូមចំរើនពរ និងជំរាបជូនដល់ញាតិញោម ពុទ្ធបរិស័ទ សប្បុរសជនទាំងឡាយ សូមមេត្តាទានជ្រាប និងទានជ្រាប ។

រោងឧបោសថាគារ គឺព្រះវិហារជាទីសក្ការបូជាដ៏ប្រសើរ ដែលព្រះតេជគុណ លោក លោកស្រី ពុទ្ធបរស័ទ សប្បុរសជន ក្នុងរដ្ឋមិនីសូតា និងរដ្ឋនានា បានរួមសាមគ្គីដោយសទ្ធាជ្រះថ្លា ធ្វើការបរិច្ចាគនូវបច្ច័យ ដើម្បីជួយឧបត្ថម្ភដល់ការស្ថាបនានោះ ឥឡូវនេះ បានសាងសង់ចប់សព្វគ្រប់ជាស្ថាពរហើយ ។

ខ្ញុំព្រះករុណាអាត្មាភាព យើងខ្ញុំក្រុមអភិបាល ពុទ្ធបរិស័ទ បានឯកច្ឆន្ទនឹងរៀបចំពិធីបុណ្យពុទ្ធាភិសេក បុណ្យបញ្ចុះខ័ណ្ឌសីមា សម្ពោធឆ្លងព្រះវិហារថ្មី នៅវត្តមុនីសុតារាម តាមប្រពៃណីនៃព្រះពុទ្ធសាសនា ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ៥-៦-៧-៨ ខែកក្កដា ព.ស ២៥៥១ គ.ស. ២០០៧ ។

ហេតុដូចបានប្រគេន និងជំរាបជូនដំណឹងខាងលើនេះ សូមគោរពនិមន្តព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ គោរពអញ្ជើញ ពុទ្ធបរិស័ទ សប្បុរសជន លោកតា លោកយាយ លោកមា លោកមីង លោក លោកស្រី បងប្អូនគ្រប់ទិសទី និមន្តនិងអញ្ជើញចូលរួមក្នុងពិធីបុណ្យខាងលើនេះ ដើម្បីទទួលអនុមោទនានូវមគ្គផល កុសលចេតនា ផលានិសង្ស រៀងៗព្រះអង្គ និងរៀងៗខ្លួនដោយសោមនស្ស និងសទ្ធាជ្រះថ្លា ។

## កាលបរិច្ឆេទបុណ្យ

ថ្ងៃព្រហស្បតិ៍ ទី៥ ខែកក្កដា ព.ស. ២៥៥១ គ.ស. ២០០៧

| | | |
|---|---|---|
| វេលាម៉ោង ៧:០០ ព្រឹក | : | ប្រគេនយាគូដល់ព្រះសង្ឃ |
| វេលាម៉ោង ៩:៣០ ព្រឹក | : | ជួបជុំពុទ្ធបរិស័ទ នមស្សការ សមាទានសីល រាប់បាត្រ |
| វេលាម៉ោង ១១:០០ ព្រឹក | : | វេរភត្តប្រគេនដល់ព្រះសង្ឃ |
| វេលាម៉ោង ២:០០ រសៀល | : | ដង្ហែនាគ និងពិធីបំបួសសាមណេរ និងឧបសម្បទាភិក្ខុ |

វេលាម៉ោង ៧:០០ ល្ងាច : នមស្សការ សមាទានសីល ពិធីអភិសេកព្រះពុទ្ធបដិមា អង្គព្រះជីវ៏ ព្រះវិហារជាន់ខាងលើ និងទេសនាបឋមត្រាស់ ។

## ថ្ងៃសុក្រ ទី៦ ខែកក្កដា ព.ស. ២៥៥១ គ.ស. ២០០៧

វេលាម៉ោង ៧:០០ ព្រឹក : ប្រគេនយាគូដល់ព្រះសង្ឃ

វេលាម៉ោង ៩:៣០ ព្រឹក : ពិធីធ្វើកិច្ចនមស្សការ សមាទានសីល រាប់បាត្រ

វេលាម៉ោង ១១:០០ ព្រឹក : វេរភត្តប្រគេនដល់ព្រះសង្ឃតាមទិស

វេលាម៉ោង ២:០០ រសៀល : គោរពទង់ ដង្ហែថ្មសីមា និងត្រៃចីវរប្រទក្សិណព្រះវិហារបីជុំ

វេលាម៉ោង ៣:០០ ល្ងាច : នមស្សការ សុំសីល វេរព្រះវិហារ និងនិមិត្តសីមាដល់ព្រះសង្ឃ ចំរើនព្រះបរិត្ត ធម្មទេសនា សង្គាយនាត្រៃគីពីរ

វេលាម៉ោង ៦:០០ ដល់ ម៉ោង ១០:០០ យប់ : សំដែងសិល្បៈជូនទស្សនិកជនកំសាន្ត

## ថ្ងៃសៅរ៍ ទី៧ ខែកក្កដា ព.ស. ២៥៥១ គ.ស. ២០០៧

វេលាម៉ោង ៧:០០ ព្រឹក : ប្រគេនយាគូដល់ព្រះសង្ឃ

វេលាម៉ោង ៩:៣០ ព្រឹក : ពិធីធ្វើកិច្ចនមស្សការ សមាទានសីល ព្រះសង្ឃបិណ្ឌបាត្រ

វេលាម៉ោង ១១:០០ ព្រឹក : វេរភត្តប្រគេនដល់ព្រះសង្ឃតាមទិស

វេលាម៉ោង ១:៣០ រសៀល : ព្រះសង្ឃធ្វើពិធីសូត្របញ្ចុះសីមា

វេលាម៉ោង ៤:០០ ល្ងាច : ធម្មទេសនា សង្គាយនាត្រៃគីបី

វេលាម៉ោង ៦:០០ ដល់ ម៉ោង ១០:០០ យប់ : សំដែងសិល្បៈជូនទស្សនិកជនកំសាន្ត

## ថ្ងៃអាទិត្យ ទី៨ ខែកក្កដា ព.ស. ២៥៥១ គ.ស. ២០០៧

វេលាម៉ោង ៧:០០ ព្រឹក : ប្រគេនយាគូដល់ព្រះសង្ឃ

វេលាម៉ោង ៩:៣០ ព្រឹក : ពិធីធ្វើកិច្ចនមស្សការ សមាទានសីល ព្រះសង្ឃបិណ្ឌបាត្រ

វេលាម៉ោង ១១:០០ ព្រឹក : វេរភត្តប្រគេនដល់ព្រះសង្ឃតាមទិស

វេលាម៉ោង ១:៣០ រសៀល : កម្មវិធីពិសេសលើវេទិកាកិត្តិយស និងកាត់ខ្សែបូ

វេលាម៉ោង ៤:០០ ល្ងាច : កម្មវិធីសូត្រកាត់ឫសសីមា និងពហូទេវាឆ្លងបុណ្យ

វេលាម៉ោង ៦:០០ ដល់ ម៉ោង ១០:០០ យប់ : សំដែងសិល្បៈជូនទស្សនិកជនកំសាន្ត ។

ពុទ្ធិកសមាគមខ្មែរ វត្តមុនីសុតារាម រដ្ឋមិនីសុតា

THE MINNESOTA CAMBODIAN BUDDHIST SOCIETY; INC.
A NON-PROFIT RELIGIOUS INCORPORATION
2925 220th Street East, Hampton, MN 55031 Tel: (651) 463-3101 Fax: (651) 460-4464
http://www.wattmunisota.org

# Consecration of Buddha Image, Consecration of Sima Boundary, and Inauguration of New Temple

The Minnesota Cambodian Buddhist Society, Inc. of Munisotaram Temple, is pleased to announce that the construction of the New Temple of Watt Munisotaram has been completed, thanks to your cooperation and financial supports. The celebration of Consecration of the Buddha Image, Consecration the Sima Boundary, and inauguration of the New Temple will take place in July 5, 6, 7, and 8, 2007 according to the following schedule:

## SCHEDULE

### Thursday, July 05, 2007

7:00 AM : Serving breakfast for Buddhist Monks
9:30 AM : Paying respect to the Triple Gem; Taking the Five Precepts;
11:00 AM : Offering Lunch to Buddhist Monks
2:00 PM : Parade of ordaining of Novices and Monks.
7:00 PM : Paying respect to the Triple Gem; Taking the Five Precepts; Chanting for the consecration of the Buddha Image, and Sermon.

### Friday, July 06, 2007

7:00 AM : Serving breakfast for Buddhist Monks
9:30 AM : Homage to the Triple Gem; Taking the Five Precepts; Offering Alms (Rob Batt).
11:00 AM : Offering Lunch to Buddhist Monks
2:00 PM : Salute the Flag and Circumambulation of Sima Stones
3:00 PM : Paying respect to the Triple Gem; Taking the Five Precepts; Chanting; and Sermon (Dhammadesna).
6:00 PM to 10:00 PM: Traditional Dance and Live Band.

Saturday, July 07, 2007

7:00 AM : Serving breakfast for Buddhist Monks
9:30 AM : Homage to the Triple Gem; Taking the Five Precepts; Alms Offering (Rob Batt).
11:00 AM : Offering Lunch to Buddhist Monks
1:30 PM : Chanting for Marker set up the Sima by Buddhist Monks.
4:00 PM : Give Sermon (Dhammadesna).
6:00 PM to 10:00 PM: Traditional Dance and Live Band.

Sunday, July 08, 2007

7:00 AM : Serving breakfast for Buddhist Monks
9:30 AM : Homage to the Triple Gem; Taking the Five Precepts; Alms offering (Rob Batt).
11:00 AM : Offering Lunch to Buddhist Monks
1:30 PM : Remarks, Cutting Ribbon to inaugurate the New Temple.
4:00 PM : Main Root Sima Cutting Ceremony
6:00 PM to 10:00 PM: Traditional Dance and Live Band.

You, your relatives and friends are cordially invited to participate in our Consecration of the Buddha Image, Consecration of the Sima Boundary, and inauguration the New Temple.